**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ.................................

# កំណត់ហេតុ

## នៃកិច្ចប្រជុំពិភាក្សារវាងគណៈកម្មាធិការជាតិ គ.ជ.ប.ជ ជាមួយតំណាងស្ថានទូតអាមេរិក និងអង្គការអភិវឌ្ឍន៍ USAID ស្តីពីកិច្ចសហប្រតិបត្តិការជាមួយអាមេរិក ដែលជួយគាំទ្រក្នុងការលើកកម្ពស់កិច្ច ខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីឈានទៅរកចំណាត់ថ្នាក់នៅឆ្នាំបន្តបន្ទាប់

កាលពីថ្ងៃសុក្រ ១៥ប្រាំកើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០នាទីរសៀល នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំកិច្ចប្រជុំរវាងពិភាក្សារវាងគណៈកម្មាធិការជាតិ គ.ជ.ប.ជ ជាមួយតំណាងស្ថានទូតអាមេរិក និងអង្គការអភិវឌ្ឍន៍ USAID ស្តីពីកិច្ចសហប្រតិបត្តិការជាមួយអាមេរិក និងជួយគាំទ្រក្នុងការលើកកម្ពស់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីឈានទៅរកចំណាត់ថ្នាក់នៅឆ្នាំបន្តបន្ទាប់។ ដែលមានសមាសភាពចូលរួមចំនួន ១៥នាក់ (ស្រី ០៤នាក់)។

## ១.សមាសភាពចូលរួម

ក.ខាងកម្ពុជា

លោកជំទាវ **ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ជាប្រធានដឹកនាំកិច្ចប្រជុំ លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណា សំខាន់** អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងឯកឧត្តម លោកជំទាវអគ្គលេខាធិការរង លោក លោកស្រីប្រធាន អនុប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ គ.ជ.ប.ជជាច្រើនរូបទៀត។

ខ.ខាងសហរដ្ឋអាមេរិក

ដឹកនាំដោយ លោក Luis Salas តំណាងឱ្យឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា និងលោកស្រី **Hanh** តំណាងអង្គការអភិវឌ្ឍន៍ USAID និងអ្នកជំនាញឯកទេសបកប្រែភាសាចំនួន ០២រូបទៀត។

## ២. គោលបំណង

- ដើម្បីឆ្លើយតប និងធ្វើការបំភ្លឺនូវអនុសាសន៍ទាំង១៧ ដែលអាមេរិកបានស្នើឱ្យកម្ពុជានៅក្នុងរបាយការណ៍វាយតម្លៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២០។
- ដើម្បីពង្រឹងកិច្ចសហការរវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើឲ្យប្រសើរឡើងនូវសកម្មភាព និងលទ្ធផល នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ។

## ៣.មតិស្វាគមន៍ និងចំណាប់អារម្មណ៍

ជាកិច្ចចាប់ផ្តើមខាងកម្ពុជាក៏បានណែនាំបញ្ជាក់ពីតួនាទីរបស់ខ្លួនម្នាក់ម្តងៗ ជូនភ្ញៀវខាងសហរដ្ឋអាមេរិក ចំណែកឯខាងប្រតិភូសហរដ្ឋអាមេរិកក៏បានណែនាំបញ្ជាក់ពីតួនាទីរបស់ខ្លួនម្នាក់ម្តងៗផងដែរ។ តបតាមការអញ្ជើញចូលរួមកិច្ចសន្ទនាទ្វេភាគីក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានដូចខាងក្រោមនេះ៖

លោកស្រី **Hanh** តំណាងអង្គការអភិវឌ្ឍន៍ USAID បានមានមតិថា យើងខ្ញុំយល់ពីការពិតចំពោះ លោកជំទាវ និងឯកឧត្តម និងសូមថ្លែងអំណរគុណដែលបានសហការគ្នា និងពិតជាធ្វើការងារនេះបានល្អប្រសើរ ជាពិសេសខាងភាគីកម្ពុជា។ ឥឡូវនេះយើងនឹងចាប់ផ្តើមដោយធ្វើការលើកឡើងអំពីគោលគំនិត និងមតិយោបល់របស់អ្នក តើយើងអាចធ្វើអ្វីបានទៅលើអនុសាសន៍ទាំង ១៧ចំណុច និងបានថ្លែងអំណរគុណនៅក្នុងកិច្ចប្រជុំនេះ។

លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍ថា យើងចាប់តាំងពីបានជួបពិភាក្សាជាមួយគណៈប្រតិភូស្ថានទូតអាមេរិករួចមក ដោយបានបញ្ជាក់ទៅលើអនុសាស្ត្រទាំង ១៧ចំនុចដូចតទៅៈ

១-យើងមានការងារមួយចំនួនដែលត្រូវបន្តផ្តោតលើការយកចិត្តទុកដាក់បំផុត ហើយយើងនឹងបន្តធ្វើការងារនេះដើម្បីបានលទ្ធផលជាក់លាក់ជាមុខនៃការងារយុត្តិធម៌ ហើយកន្លងមកយើងទទួលស្គាល់ការងារកន្លងមកដែលមានការខ្វះចន្លោះគឺនៅត្រង់ការពិនិត្យរបាយការណ៍ ទោះបីជាមានការខិតខំប្រឹងប្រែង ប៉ុន្តែហាក់បីដូចជាមិនប្រព្រឹត្តទៅលើអ្វីដែលការវាយតម្លៃរបស់សហរដ្ឋអាមេរិកចង់បាន។ ឥឡូវនេះយើងចាប់ផ្តើមរៀបចំនិតិវិធីប្រមូលរបាយការណ៍ ឧទាហរណ៍ពាក់ព័ន្ធនឹងបញ្ហាទិន្នន័យរបាយការណ៍ ដូច្នេះយើងកំពុងតែសហការគ្នា តើយើងជួយគាំទ្រដល់ក្រសួងយុត្តិធម៌យ៉ាងដូចម្តេច? ដើម្បីប្រមូលនូវព័ត៌មានឱ្យទាន់ពេលវេលា។

២-ទាក់ទងនឹងវិធីសាស្ត្រនៃការស៊ើបអង្កេត កន្លងមកយើងបានជជែកគ្នាថាធ្វើការពិភាក្សារវាងក្រសួងយុត្តិធម៌ និងក្រុមអ្នកជំនាញបច្ចេកទេសស៊ើបអង្កេត ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់នៅក្នុងកំរិតណា ឬមួយត្រូវធ្វើយ៉ាងដូចម្តេច? ហើយលោកជំទាវក៏ចង់ដឹងដែរថាតើបានធ្វើរឿងហ្នឹងឬនៅ ដែលទាក់ទងទៅនឹងកិច្ចប្រជុំពិភាក្សាផ្នែកកំរិតជំនាញ ដើម្បីយើងជជែកគ្នា។

៣-ទាក់ទងនឹងកញ្ចប់ថវិកាយើងមានរបៀបក្នុងការឧបត្ថម្ភដល់កិច្ចសហប្រតិបត្តិការ ក៏ប៉ុន្តែកំណត់ប៉ុណ្ណានោះវាទាក់ទងទៅនឹងទំហំថវិកាដែលខ្លួនមាន ហើយរបៀបធ្វើការងារនេះយើងមានទាំងនីតិវិធីក្នុងការផ្តត់ផ្គង់នៃការធ្វើកិច្ចសហប្រតិបត្តិការ និងសូមបញ្ជាក់ថាទំហំនៃថវិកា គឺវាអាស្រ័យទៅលើការអនុម័តរបស់ក្រសួងហិរញ្ញវត្ថុ និងរដ្ឋាភិបាលប៉ុណ្ណោះ។

៤-ការទាក់ទងកំណត់អត្តសញ្ញាណនៃជនរងគ្រោះ គឺយើងកំពុងតែធ្វើការបណ្តុះបណ្តាលបន្ថែម ហើយបន្តទៅទៀតយើងជំរុញឱ្យមានការតាមដានប្រមូលលទ្ធផល ពីព្រោះយើងមានក្រុមខ្សែបណ្តាញហើយ គ្រាន់តែថាតើការអនុវត្តទៅវាបានយ៉ាងដូចម្តេច ឬមួយយើងជំរុញឱ្យមានការតាមដានទៅលើការអនុវត្ត និងកំពុងតែបន្ថែមសមាសភាពដែលមានភារកិច្ចសហការជាមួយអង្គការដៃគូមួយចំនួន ដែលត្រូវធ្វើការបើកវគ្គបណ្តុះបណ្តាលបន្ថែម ឧទាហរណ៍យើងបានធ្វើការងារនេះនៅខេត្តបាត់ដំបង ពីព្រោះយើងចង់ឱ្យអ្នកអនុវត្តទាំងនោះយល់ច្បាស់ក្នុងការអនុវត្តនីតិវិធីក្នុងការតាមដានជនសង្ស័យដែលនៅក្រៅឃុំ។

៥-តាមការពិតវាមិនទាក់ទងទៅនឹងការបន្ថែមធនធានទៀតទេ សំខាន់ការធ្វើនីតិវិធីវាទាក់ទងឱ្យយើងត្រូវពិភាក្សាឡើងវិញជាមួយវិស័យយុត្តិធម៌។ ដើម្បីឱ្យដឹងថាការតាមដានជនសង្ស័យដែលនៅក្រៅឃុំ យើងមាននីតិវិធីសម្រាប់ការអនុវត្តនៃភាពជាក់លាក់ ហើយយើងតែងតែគិតថាតើវាមានការខ្វះចន្លោះត្រង់ណា ប្រហែលមកពីខ្វះថវិកា ឬខ្វះជំនាញបច្ចេកទេស។ បើតាមការគិតរបៀបនេះប្រហែលជាយើងត្រូវធ្វើការជាមួយអង្គការ IJM ព្រោះ IJMក៏មានវាគ្មិនជួយគាំទ្រការងារនេះដែរ។

៦-ចំពោះការចុះអធិការកិច្ចទាក់ទងទៅនឹងជនរងគ្រោះ យើងនឹងជំរុញធ្វើការងារនេះបន្ថែមទៀតទៅដល់ក្រុមអធិការកិច្ច ក្នុងនោះយើងឯកភាពនូវភាពខ្វះចន្លោះចំពោះការធ្វើអធិការកិច្ចកន្លងមក បើមុននឹងធ្វើត្រូវមានការជូនដំណឹងជាមុន តែការធ្វើមិនបានជូនដំណឹងមុនទេ ដូច្នេះយើងត្រូវតែមានការគិតរកនីតិវិធីនេះ។

៧-ចំពោះសេវាកម្មជនរងគ្រោះជាបុរស យើងកំពុងតែពិភាក្សាគ្នានៅថ្ងៃទី២១ ខែតុលាខាងមុខនេះ យើងនឹងជជែកគ្នាជាមួយក្រុមការងារផ្សេងទៀត ដើម្បីជំរុញឱ្យសេវាកម្មក្នុងការជួយជនរងគ្រោះដែលកំពុងមានគ្រោះថ្នាក់។

៨-យើងនឹងពិភាក្សាគ្នា នៅថ្ងៃទី ០៨ ខែតុលាខាងមុខនេះ ពាក់ព័ន្ធនឹងការតាមដាន និងប្រមូលទិន្នន័យអំពីការផ្តន្ទាទោស ហើយយើងក៏បានដឹងដែរថាចំពោះក្រសួងយុត្តិធម៌ កំពុងតែសង្គ្រោះជនរងគ្រោះដែលអនុវត្តដោយក្រសួងយុត្តិធម៌។ យើងមានកិច្ចសហប្រតិបត្តិការមួយចំនួន ជាមួយអង្គការអាស៊ានអាក់ និងក្រុមការងារមួយចំនួនទៀត ហើយគួតែមានអង្គការមួយចំនួនដែលត្រូវធ្វើការងារនេះ។ យើងឃើញថាមានក្រុមការងារយុត្តិធម៌កំពុងរៀបចំប្រមូលទិន្នន័យ ដោយមានអ្នកទទួលខុសត្រូវជាមុន និងមានទាំងរដ្ឋលេខាធិការមួយរូបក្នុងការទទួលបន្ទុក

ទិន្នន័យនេះ ស្របពេលដែលមានយុទ្ធនាការសម្រាប់ការដោះស្រាយបណ្ដឹងកកស្ទះ ដោយមានការញែកឱ្យដាច់អំពីបទល្មើសជួញដូរផងដែរ។

៩-ចំពោះការលុបបំបាត់ការរំលោភបំពានការងារទៅលើពលករ យើងត្រូវមានការពិភាក្សាជាមុនសិន ដែលត្រូវពាក់ព័ន្ធជាមួយក្រសួងការងារ ក៏ដូចជាវិស័យឯកជន ដើម្បីរកវិធីសាស្ត្រក្នុងការកែលម្អ និងសូមឱ្យអង្គការដៃគូត្រូវចូលរួមជាមតិផ្ដល់យោបល់ផងដែរ។

១០-ធ្វើអធិការកិច្ចលើស្ថាប័ន ដើម្បីពិនិត្យលើការឱ្យប្រាក់កម្ចីដោយមីក្រូហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយភាពរងគ្រោះ ដោយមិនមានការបង្ខិតបង្ខំ ប៉ុន្តែមានរឿងមួយទៀតពាក់ព័ន្ធកម្ចីជាមួយថៅកែជ្រើសរើសពលករ ឬវិស័យជ្រើសរើសឯកជន ពីព្រោះបើនិយាយអំពីគោលនយោបាយរបស់មីក្រូហិរញ្ញវត្ថុ គឺវាជាក់លាក់ គ្រាន់តែយើងតាមដានអំពីរបៀបក្នុងការផ្ដល់ប្រាក់កម្ចី បើទាក់ទងនឹងវិស័យឯកជនដែលមិនមែនផ្លូវការណ៍។

១១-បើនិយាយអំពីជនរងគ្រោះដែលជាជនរងគ្រោះជាជនជាតិខ្មែរ និងជនជាតិបរទេស ជានីតិវិធីរបស់តុលាការផ្ដល់ការអនុញ្ញាតធ្វើការជំនុំជម្រះ គឺវាពាក់ព័ន្ធទៅនឹងនីតិវិធីច្បាប់អន្តោប្រវេសន៍ដែលយើងត្រូវជជែកគ្នា តើនៅក្នុងនីតិវិធីនោះគេចោទជាបទល្មើសកំរិតណា?ដែលយើងបានធ្វើហើយ ប៉ុន្តែយើងត្រូវការឱ្យមានទិន្នន័យដែលបានបញ្ជាក់ថាត្រូវនឹងរឿងហ្នឹងមែន។

១២-ការដែលឱ្យមានសំណងបដិទាន តាមពិតច្បាប់ចេញហើយ សំណងបដិទាននេះមានតែនៅក្នុងច្បាប់ ប៉ុន្តែអ្វីដែលយើងបារម្ភ គឺនីតិវិធី និងការអនុវត្ត ដូច្នេះពាក់ព័ន្ធនឹងបញ្ហាច្បាប់នេះ គឺត្រូវការពិភាក្សាជាមួយក្រសួងយុត្តិធម៌ ដើម្បីឱ្យច្បាស់ថាតើត្រូវធ្វើដូចម្ដេច ដើម្បីឱ្យមានសំណងបដិទាន។ សូមជម្រាបថា កន្លងមកភាពរងគ្រោះរបស់ពលករ គឺវាទាក់ទងនឹងវិស័យការងារភាគច្រើននៅក្រៅប្រទេស ហើយអ្វីដែលយើងមិនអាចអនុវត្តបានដោយសារខ្វះអត្តសញ្ញាណគឺវាទាក់ទងពលករទាំងនោះមិនបានប្រើប្រាស់នូវឯកសារស្របច្បាប់ ហើយដល់ពេលពួកគាត់មានគ្រោះថ្នាក់ ពេលនោះពួកគាត់មិនបានសំណងបដិទានទេ។ ដូច្នេះបញ្ហាសំណងបដិទាននេះវាកើតឡើងមិនមែននៅក្នុងប្រទេសកម្ពុជាទេ គឺសម្រាប់តែពលករនៅក្រៅប្រទេសប៉ុណ្ណោះ។

១៣-ក្រសួងការបរទេសបានបង្កើតថវិកាបម្រុងសម្រាប់ពលករនៅក្រៅប្រទេសមានបញ្ហា ហើយក៏បានបង្កើនថវិកានេះជារៀងរាល់ឆ្នាំ។ ប៉ុន្តែពាក់ព័ន្ធទៅដល់ការជួយជនរងគ្រោះដោយសារអំពើជួញដូរមនុស្សតែមួយមុខ ដូច្នេះការប្រើប្រាស់ថវិកានេះនៅតែខ្វះខាត ដោយសារជនរងគ្រោះនៅក្រៅប្រទេសនោះមានការកើនឡើងកាន់តែច្រើន ដូច្នេះការបង្កើនថវិកា វាអាស្រ័យនឹងថវិកាជាតិ។

១៤-សព្វថ្ងៃនេះយើងកំពុងមានបញ្ហាជាមួយប្រទេសម៉ាឡេស៊ី ដោយសារនៅក្នុង MOU និយាយអំពីពលករ យើងចង់ឱ្យ MOU ពាក់ព័ន្ធនឹងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ហើយមកដល់សព្វថ្ងៃនេះយើងមិនទាន់បានចុះហត្ថលេខានៅឡើយទេ មកទល់ពេលនេះខាងម៉ាឡេស៊ីមិនបានសហការចុះ MOU ជាមួយយើងរយៈពេល១០ឆ្នាំមកហើយ គេចេះតែពន្យាពេលរហូត។ ប៉ុន្តែយើងក៏អាចរំលឹកឡើងវិញដែរ ដើម្បីឱ្យក្រសួងការងារគាត់ចេញអាជ្ញាប័ណ្ណដល់ភ្នាក់ជ្រើសពលករ។

១៥-ពាក់ព័ន្ធទៅនឹងក្រុមការងារទេសន្តរប្រវេសន៍ យើងអាចប្រើប្រាស់ក្រុមនេះឡើងវិញទៅលើគោលនយោបាយពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍។ មិនពាក់ព័ន្ធនឹងមេខ្យល់ និងមិនបានទទួលសិទ្ធិនេះទេ ពីព្រោះមេខ្យល់ជាអ្នកធ្វើការងារខុសច្បាប់ ហើយគាត់នាំយកពលករទៅធ្វើការងារខុសច្បាប់។ ត្រង់ចំណុចនេះយើងឯកភាព ព្រោះយើងត្រូវធ្វើការស្រាវជ្រាវជនក្លែងបន្លំនៅតាមក្រុមហ៊ុន ឬធ្វើការនៅក្រៅប្រទេស ដែលយើងត្រូវធ្វើការស៊ើបអង្កេត ផ្ដន្ទាទោស ឬបង្ក្រាប។

១៦-យើងនឹងជំរុញកិច្ចសហការជាមួយក្រុមការងារទេសន្តរប្រវេសន៍ ដើម្បីយើងពង្រឹង ឬលើកកម្ពស់នីតិវិធីក្នុងការផ្សព្វផ្សាយឱ្យកាន់តែល្អប្រសើរឡើង។

១៧-យើងចង់ឱ្យអង្គការដៃគូ ពង្រឹងសិទ្ធក្នុងការថែទាំកុមារ និងពង្រឹងស្ថានីតិសម្បទាឱ្យកាន់តែប្រសើរឡើង ហើយយើងបានពិភាក្សាគ្នាជាមួយក្រសួងសង្គមកិច្ច និងក្រសួងយុត្តិធម៌ ដើម្បីផ្ដល់សិទ្ធដល់អង្គការដៃគូនូវនីតិសម្បទា

ដល់ជនរងគ្រោះដើម្បីរកយុត្តិធម៌ យើងនឹងបន្តធ្វើការងារនេះនៅក្នុងឆ្នាំថ្មីទៀត ថាតើដំណើរនៃការផ្តល់ស្តានីតិសម្បទារ វាមានដំណើរយ៉ាងដូចម្តេចខ្លះ?។

លោកស្រី **Hanh** តំណាងអង្គការអេភិវឌ្ឍន៍ USAID បានមានមតិថា ទីស្នាក់ការរបស់គាត់ទើបតែធ្វើគម្រោងបញ្ចប់ ហើយទីស្នាក់ការរបស់គាត់កំពុងផ្តោតទៅលើគណៈកម្មាធិការជាតិ គ.ជ.ប.ជ គាត់ក៏មិនអាចបង្កើតគម្រោងថ្មីមួយទៀតដែលមានទឹកប្រាក់រាប់លានដុល្លារយៈពេលខ្លីនោះបានទេ ហើយបច្ចុប្បន្នគឺយើងត្រូវគិតគូរឱ្យទាន់សភាពការណ៍ ដើម្បីឆ្លើយតបនឹងអនុសាសន៍ទៅនឹងរបាយការណ៍របស់ប្រទេសនៅក្នុងតំបន់ឆាងអានទន្លេមេគង្គ អញ្ចឹងអ្វីដែលយើងធ្វើបាននោះ បើសិនលោកជំទាវអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិមានចំណាប់អារម្មណ៍ យើងអាចដកលក្ខណៈទី១ចេញ តាមរយៈទីប្រឹក្សា APEC និងសំខាន់ខាងគណៈកម្មាធិការជាតិមានរបាយការណ៍ក្នុងការសម្របសម្រួលឱ្យមានទិន្នន័យ ក៏ដូចជាការសម្របសម្រួលខាងរដ្ឋាភិបាល ឬសង្គមស៊ីវិល ឬខាង APEC នោះវាអាចធ្វើការជាមួយគ្នាបាន ។

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ បានមានប្រសាសន៍ឆ្លើយតបតាមគោលគំនិតរបស់ **លោកស្រី Hanh** តំណាងអង្គការអេភិវឌ្ឍន៍ USAID និងមានការសម្របសម្រួលក្នុងសកម្មភាពរបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ដែលបានអនុវត្តកន្លងមក និងសូមឱ្យមានកិច្ចសហប្រតិបត្តិការជាមួយគ្នាបន្តធ្វើការងារនេះ ដើម្បីធ្វើឱ្យគណៈកម្មាធិការជាតិយើងបានទទួលរបាយការណ៍ដែលមានទិន្នន័យជាក់លាក់ទៅឆ្នាំបន្តទៀត។

លោកស្រី **Hanh** តំណាងអង្គការអេភិវឌ្ឍន៍ USAID បានមានមតិបន្តទៀតថា ទីស្នាក់ការខាងអង្គការរបស់លោកស្រីចង់មានវិធានការការពារកុំឱ្យមានចំណាកស្រុកដោយអសុវត្ថិភាព ហើយជាធម្មតាគម្រោង USAID ចង់ជួយទៅដល់ពលរដ្ឋរងគ្រោះ ឱ្យពួកគាត់មានការងារធ្វើត្រឹមត្រូវ ទាំងនៅសហគមន៍របស់គាត់ យើងបានចែករំលែកដោយធ្វើការបណ្តុះបណ្តាលដល់ពួកគាត់ឱ្យចេះចិញ្ចឹមសត្វ ការដាំបន្លែ និងរកទីផ្សារឱ្យពួកគាត់ថែមទៀត ហើយនៅក្នុងពេលជាមួយគ្នានោះ យើងមានការបញ្ជ្រាបទាក់ទងនឹងព័ត៌មាន តើត្រូវធ្វើយ៉ាងម៉េចដើម្បីអាចឱ្យពួកគាត់ការពារខ្លួនឯងបាន ឬហាមពួកគាត់កុំឱ្យធ្វើចំណាកស្រុកដោយប្រថុយប្រថាន និងកុំឱ្យពួកគាត់មានបញ្ហា ឬមានគ្រោះថ្នាក់អ្វីចំពោះពួកគាត់។ លោកស្រីបានអរគុណច្រើននូវព័ត៌មានដែល**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ ចែករំលែកជាច្រើន ហើយលោកស្រីស្នើ៥ចំណុច ដែលជាអនុសាសន៍បញ្ជាក់បន្ថែមនៅក្នុងកិច្ចសហប្រតិបត្តិការ ដូចមានៈ ទី១ ស្តីពីបញ្ហានៃការចែករំលែកព័ត៌មានពាក់ព័ន្ធជាមួយករណីរបស់តុលាការនៃក្រសួងយុត្តិធម៌។ ទី២ គឺពាក់ព័ន្ធនឹងការកំណត់អត្តញ្ញាណជនរងគ្រោះ។ ទី៣ គឺទាក់ទងនឹងការអនុញ្ញាតឱ្យប្រើប្រាស់នូវការស៊ើបអង្កេតជា UIA ។ ទី៤ បង្កើនការត្រួតពិនិត្យលើការងារដោយប្រកាសជាមុននៅក្នុងចំណោមការងារជនរងគ្រោះ។ ទី៥ បង្កើនការត្រួតពិនិត្យលើស្ថាប័នផ្តល់ប្រាក់កម្ចី ឬទីភ្នាក់ងារដែលធ្វើនៅក្នុងវិស័យការងារ ដោយឱ្យមានការតាមដាន ទាំងនេះជា៥ចំណុច ដែលរកឃើញដោយគណៈកម្មាធិការជាតិ គ.ជ.ប.ជ ផ្តោតនៅក្នុងរយៈពេលខ្លីដែលយើងអាចផ្តោតទៅលើ FUND ក្នុងការវាយតម្លៃចំណាត់ថ្នាក់ក្នុងឆ្នាំបន្ទាប់ ជាមួយគ្នានោះដែរទាក់ទងនឹងអនុសាសន៍៥ចំណុចនេះ យើងនឹងធ្វើការងារនេះដ៏ដែល គឺវាពាក់ព័ន្ធកិច្ចសហប្រតិបត្តិការរយៈពេលយូរអង្វែង និងវាទាក់ទងនឹងសមត្ថភាពរបស់រដ្ឋាភិបាល ក៏ដូចជាគណៈកម្មាធិការជាតិ គ.ជ.ប.ជ។

**លោកជំទាវអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ បានមានប្រសាសន៍សង្កត់ទៅលើចំណុចទី៣ និងសូមអរគុណហើយក៏បានបញ្ជាក់ថា វាជាចំណុចដែលត្រូវគិត និងក៏មិនមែនជាការងារចេញឆាប់ៗនេះដែរ គឺយើងត្រូវតែពិចារណាថាយើងនឹងចាប់ផ្តើមរកនីតិវិធីការងារណាមួយ ឧទាហរណ៍ទាក់ទងនឹង UIA សុំឱ្យក្រុមការងារមានការជជែកគ្នា ប្រសិនបើថាតើត្រូវធ្វើយ៉ាងម៉េច ប៉ុន្តែយើងនឹងពិនិត្យការងារនេះ ហើយយើងនឹងចាប់យកការអនុវត្តការងារនេះ ចំណុចទាំង៥នោះវាស្ថិតនៅក្នុងនីតិវិធីយើងនឹងខិតខំជំរុញវា ក៏ប៉ុន្តែយើងត្រូវប្រើពេលវេលា។

លោក Luis Salas តំណាងឱ្យឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា ទាក់ទងនឹងអនុសាសន៍ទាំង៥នោះគាត់ចង់ផ្តោតទៅលើចំណុចទី១ ដែលផ្តោតទៅលើការរាយការណ៍ក្នុងករណីតុលាការ ខ្ញុំចង់ជម្រាបលោកជំទាវ

ថាវាពាក់ព័ន្ធនឹងក្រសួងយុត្តិធម៌ ហើយក្នុងដំណាក់កាលនេះយើងកំពុងធ្វើការវាយតម្លៃ នៅពេលនោះខាងស្ថានទូតកំពុងធ្វើការទំនាក់ទំនងជាមួយក្រសួងយុត្តិធម៌តែម្តង។

លោកជំទាវស្នើសុំឱ្យលោក Luis Salas បញ្ជាក់អំពី UIA ៖

លោក Luis Salas ទាក់ទងនឹងចំណុចទី៣ ពាក់ព័ន្ធនឹងវិធីសាស្ត្រនៃការស៊ើបអង្កេតសំងាត់ ខាងស្ថានទូតបានពិភាក្សាជាមួយផ្នែកជាប់ពាក់ព័ន្ធនឹងស្ថានទូត ហើយយើងនឹងពិភាក្សាជាមួយលោកជំទាវ និងជាមួយនគរបាល ដែលពាក់ព័ន្ធនឹងការពិភាក្សាលើកទី៣នេះ យើងសង្ឃឹមថានឹងបានជួបគ្នាលើកក្រោយៗទៀត។

លោកជំទាវ ជូ ប៊ុនអេង មានប្រសាសន៍ថា ចង់ដឹងការរំលឹកឡើងវិញទៅលើនគរបាល ហើយដើម្បីថាតើពេលណាយើងត្រូវរំលឹកឡើងវិញខាងនគរបាល អញ្ចឹងនៅក្នុងទម្រង់នគរបាលអន្តរជាតិត្រូវតែកំណត់ទៅលើការងារអ្វីមួយ។

លោកស្រី **Hanh** តំណាងអង្គការអភិវឌ្ឍន៍ USAID បានមានមតិបន្ថែមទៀតថា សូមអរគុណ ហើយនឹងសង្ឃឹមថាយើងនឹងពិភាក្សាគ្នាបន្តនៅថ្ងៃក្រោយទៀត និងសូមបញ្ជាក់ទៅលើការងារពីរបន្ថែម ទី១ពាក់ព័ន្ធទៅលើគម្រោងថ្មីរបស់ USAID ដែលត្រូវបន្តពីគម្រោងចាស់ អញ្ចឹងវាអាចយូរខែ ដែលវាយូរទៅតាមអ្នករៀបចំគម្រោង ហើយលោកស្រីនឹងខិតខំប្រឹងប្រែងបញ្ចប់វានៅរយៈពេលពីរសប្តាហ៍ទៀតក៏ថាបាន ទៅតាមលោកជំទាវចង់បាន ថាតើអ្វីដែលយើងធ្វើបាន អ្វីយើងធ្វើមិនបាន។

លោកជំទាវ រ៉ន សេរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ បានមានប្រសាសន៍ចង់សួរអំពីផ្នែកគម្រោងនេះ ខាងលោកជំទាវកំពុងធ្វើគម្រោងដែលមានទិន្នន័យមួយ វាជាទិន្នន័យមួយសំដៅទៅមូលដ្ឋានសំខាន់ណាស់ ហើយយើងរៀបចំវាឱ្យត្រូវនឹងអនុសាសន៍របស់សហរដ្ឋអាមេរិកដែលត្រូវការ ហើយអ្វីដែលលោកជំទាវបានគូបញ្ជាក់នោះ ដោយសារតែយើងរំពឹងថាតុលាការនឹងមកដល់ តុលាការថ្មីសម្រាប់គណៈកម្មាធិការជាតិ គ.ជ.ប.ជ និងបើកនៅខែមករា ឆ្នាំ២០២១ ខាងមុខនេះ អញ្ចឹងទិន្នន័យខាង USAID ប្រហែលជានៅក្នុងខែ៦ មែនឬទេ? ហើយលោកជំទាវសុំធ្វើជាអាជ្ញាកណ្តាល អញ្ចឹងហើយលោកជំទាវត្រូវតែរងចាំដល់ពេលនោះ ។

**៥.ទីបញ្ចប់**

កិច្ចប្រជុំបានបញ្ចប់ទៅដោយបរិយាកាសរីករាយ ស្និទ្ធស្នាល និងមានសញ្ញាណវិជ្ជមានបន្ទាប់ពីគណៈកម្មាធិការជាតិ គ.ជ.ប.ជ បានបំភ្លឺនូវអនុសាសន៍ទាំង១៧ចំណុច និងអនុសាសន៍៥ចំណុចទៀត តាមសំណើដែលភាគីសហរដ្ឋអាមេរិកបានស្នើឱ្យកម្ពុជាយើងបំពេញនូវភាពខ្វះចន្លោះព័ត៌មាន និងសកម្មភាពក្នុងការអនុវត្តកន្លងមក ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់ប្រាំ សូន្យ សូន្យនាទីរសៀល ថ្ងៃ ខែ ឆ្នាំដដែល៕

ថ្ងៃ ............ ខែ ............ ឆ្នាំ ............ ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០២០

**អ្នកធ្វើកំណត់ហេតុ**

16/10/2020

**ឯកភាព និងសូមគោរពជូន**

**លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ**

មេត្តាពិនិត្យ និងសម្រេចដោយក្តីគោរព។

ថ្ងៃ............ខែ............ឆ្នាំ............ទោស័ក ព.ស ២៥៦៤

ថ្ងៃទី.....៥.....ខែ.....តុលា.....ឆ្នាំ២០២០

**ប្រធានលេខាធិការដ្ឋានរដ្ឋបាល-សរុប**

ឧត្តមសេនីយ៍ទោ. **ហាន_ជីវ័ន្ត**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិ
ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# បញ្ជីវត្តមាន

ថ្ងៃ .................................. ខែ ................ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ត្រូវនឹងថ្ងៃទី ...02.... ខែ....10..... ឆ្នាំ ២០២០

..........................................................................................................

..........................................................................................................

| ល.រ | នាម គោត្តនាម/Name | ភេទ/Sex | តួនាទី/Position | អង្គភាព/Organization | លេខទូរស័ព្ទ/Phone | ហត្ថលេខា/Sign |
|---|---|---|---|---|---|---|
| ១ | លោកជំទាវ ជូ ប៊ុនអេង | ស្រី | អនុប្រធានអចិន្ត្រៃយ៍ | គណៈកម្មាធិការជាតិ គ ជ ប ជ | 012 872 639 | |
| ២ | លោកជំទាវ ប៉ុណ្ណ សំខាន់ | ស្រី | អគ្គលេខាធិការ | គណៈកម្មាធិការជាតិ គ ជ ប ជ | 012 775 311 | |
| ៣ | ឯ.ឧ. [illegible] | ប | អគ្គលេខាធិការរង | 〃 | 012 72 80 81 | |
| ៤ | ឧកញ៉ា [illegible] | ស្រី | អគ្គលេខាធិការរង | NCCT | 012 771 158 | |
| ៥ | ឯ.ឧ. [illegible] | ប្រុស | -〃- | -〃- | 071 886 7777 | |
| ៦ | ឯ.ឧ. [illegible] | ប្រុស | ប្រធាននាយកដ្ឋាន | — 〃 — | 012 856 384 | |
| ៧ | ឯ.ឧ. [illegible] | 〃 | — 〃 — | — 〃 — | 012 888 851 | |

| ល.រ | នាម គោត្តនាម/Name | ភេទ/Sex | តួនាទី/Position | អង្គភាព/Organization | លេខទូរស័ព្ទ/Phone | ហត្ថលេខា/Sign |
|---|---|---|---|---|---|---|
| | ភិន ភរ | ប្រុស | ប្រធានក្រុមជំនួយកិច្ចការ | NCCT | 010466326 | |
| | Luis Salas | M | Political Officer | U.S. Embassy | 012 549 339 | |
| | Gran Chayanhanc | M | Political Specialist | U.S Embassy | ០១២ ៩៧ ២០២ | |
| | Hanh | F | DMD | USAID | | |
| | Makara Ou | M | DG | USAID | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

សរុបចំនួន ............នាក់ (ស្រី .........នាក់)

អ្នកធ្វើរបាយការណ៍